សេចក្តីថ្លែងការណ៍រួម

ប្រទេសកម្ពុជាត្រូវចំពេញតាមការសន្យារបស់ខ្លួន ក្នុងការកែប្រែច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ

សេចក្តីថ្លែងការណ៍នេះ លើកឡើងអំពីអំពើហិង្សាក្នុងគ្រួសារ។ ប្រសិនបើអ្នកកំពុងទទួលរងអំពើហិង្សាក្នុងគ្រួសារ ឬអំពើហិង្សាផ្លូវភេទ អ្នកអាច [ទាក់ទងអង្គការណាមួយ] ដើម្បីស្វែងរកការគាំទ្រ។

អស់រយៈពេលជាច្រើនឆ្នាំមកហើយ ដែលច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ (ច្បាប់អំពើហិង្សាក្នុងគ្រួសារ) ឆ្នាំ២០០៥ ត្រូវការធ្វើការកែប្រែជាបន្ទាន់ ។ ការបន្តខកខានរបស់រាជរដ្ឋាភិបាលក្នុងការកែប្រែច្បាប់នេះ បានធ្វើឱ្យស្ត្រី កុមារ និងអ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI+) នៅទូទាំងប្រទេស បន្តប្រឈម ផលប៉ះពាល់ ដោយគ្មានកិច្ចការពារគ្រប់គ្រាន់។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាល ក្រោមការគាំទ្រពីដៃគូអភិវឌ្ឍន៍អន្តរជាតិ បានបង្ហាញវឌ្ឍនភាពឆ្ពោះទៅការធ្វើវិសោធនកម្មច្បាប់នេះ តាមរយៈការចាត់ឱ្យមានការវិភាគផ្នែកច្បាប់ គោលការណ៍ណែនាំ និងរៀបចំផែនទីបង្ហាញផ្លូវមួយ ដែលនៅតែមិនទាន់បានផ្សព្វផ្សាយជាសាធារណៈនៅឡើយ ទោះបីជាពេលវេលាបានកន្លងផុតទៅជាច្រើនឆ្នាំហើយក៏ដោយក្តី។ មកទល់នឹងពេលបច្ចុប្បន្ន សកម្មភាពទាំងនេះនៅមិនទាន់បានកែតម្រូវចំណុចខ្វះខាតដែលមាននៅក្នុងច្បាប់អំពើហិង្សាក្នុងគ្រួសារនៅឡើយទេ ហើយកង្វះការពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិលដែលពាក់ព័ន្ធ អំពីដំណើរការធ្វើវិសោធនកម្មដែលបានស្នើឡើងនេះ ក៏មិនបានបង្កើតនូវទំនុកចិត្តដែលថា ចំណុចខ្វះខាតទាំងនេះនឹងត្រូវបានដោះស្រាយប្រកបដោយអត្ថន័យពេញលេញនោះដែរ។

អំពើហិង្សាក្នុងគ្រួសារ ធ្វើឱ្យស្ត្រីនិងកុមារជាប់គាំងនៅក្នុងលំនៅឋានដែលគ្មានសុវត្ថិភាព រំខានដល់ការងារ និងការសិក្សា ព្រមទាំងបង្កការឈឺចាប់យូរអង្វែងទៅលើរាងកាយ និងផ្លូវចិត្ត។ គ្រាន់តែអង្គការលីកាដូ (LICADHO) មួយប៉ុណ្ណោះ បានកត់ត្រាថា មានមនុស្សយ៉ាងតិចណាស់ ១៨១នាក់ ត្រូវបានសម្លាប់ក្នុងករណីអំពើហិង្សាក្នុងគ្រួសារ ចាប់តាំងពីឆ្នាំ២០២០ មក ដោយក្នុងចំណោមនោះ មានស្ត្រី ២៤នាក់ កុមារី ៦នាក់ និងកុមារា ៥នាក់ ត្រូវបានសម្លាប់ក្នុងរយៈពេលត្រឹមតែពីខែកញ្ញា ឆ្នាំ២០២៥ ដល់ខែកញ្ញា ឆ្នាំ២០២៦នេះ។ ជនរងគ្រោះជាច្រើនបានស្វែងរកជំនួយមុនពេលពួកគេស្លាប់ ប៉ុន្តែអាជ្ញាធរមួយចំនួនបានត្រឹមតែធ្វើការ «ការអប់រំ» ជនល្មើស និងផ្សះផ្សាដៃគូ/ប្តីប្រពន្ធឱ្យត្រឡប់រួមគ្នាវិញតែប៉ុណ្ណោះ។ ពុំមានជនរងគ្រោះណាម្នាក់ក្នុងចំណោមពួកគេ ទទួលបានវិធានការទប់ស្កាត់ ឬកិច្ចការពារគ្រប់គ្រាន់នោះឡើយ ហើយមនុស្សជាច្រើននាក់ផ្សេងទៀត នៅតែបន្តរស់ នៅក្នុងស្ថានភាពហានិភ័យនៃគ្រោះថ្នាក់ពីអំពើហិង្សាក្នុងគ្រួសារ ។

បច្ចុប្បន្ន ការគាក់តែងសេចក្តីព្រាងវិសោធនកម្មច្បាប់នេះ ត្រូវបានគ្រោងឡើងក្រោមគម្រោង «ការពង្រឹងប្រព័ន្ធជាតិសម្រាប់ការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាផ្អែកលើយេនឌ័រ»។ គម្រោងនេះ អនុវត្តដោយរាជរដ្ឋាភិបាល ក្រោមហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី ដែលរំពឹងថានឹងចាប់ផ្តើមសកម្មភាពនៅឆ្នាំក្រោយ។ អ្នកដែលធ្លាប់ទទួលរងផលប៉ះពាល់ដោយអំពើហិង្សាក្នុងគ្រួសារ និងអង្គការសង្គមស៊ីវិលនានា ត្រូវតែទទួលបានការ

ចូលរួមក្នុង «ក្រុមការងារពហុវិស័យ» ដែលនឹងត្រូវបានបង្កើតឡើងនៅក្រោមគម្រោងនេះ ដើម្បីធានាថា ច្បាប់ដែលបានធ្វើវិសោធនកម្មនោះ ឆ្លើយតបតាមតម្រូវការនានារបស់អ្នកដែលប្រឈមនឹងហានិភ័យនៃអំពើហិង្សាក្នុងគ្រួសារគ្រប់រូប ជនប្រព្រឹត្តទទួលខុសត្រូវប្រកបដោយប្រសិទ្ធភាព ព្រមទាំងហាមឃាត់ការសម្រុះសម្រួលនិងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការគ្រប់ទម្រង់ ដោយសារហេតុផលលើភាពមិនស្មើគ្នានៃទំនាក់ទំនងអំណាចដែលកើតមាននៅក្នុងការរំលោភបំពានប្រភេទទាំងនេះ។

រាជរដ្ឋាភិបាលបានបង្ហាញពីចេតនាដំបូង ក្នុងការធ្វើវិសោធនកម្មច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ ក្នុងរយៈពេលជាងមួយទសវត្សរ៍កន្លងមកហើយ។ ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០១៤–២០១៨ (NAPVAW II) បានដាក់ចេញនូវគោលបំណងពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពលើមាត្រាមួយចំនួននៃច្បាប់នេះ។ បន្ទាប់មកក៏មានការប្តេជ្ញាស្រដៀងគ្នាផ្សេងៗទៀតនេះជាបន្តបន្ទាប់ដែរ ដូចជា នៅក្នុងផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ (២០១៧–២០២១ និង ២០២៥–២០៣០) ផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី NAPVAW III (២០១៩–២០២៣) និងផែនការនារីរតនៈទី៦ (២០២៤–២០២៨)។ ទើបតែពេលថ្មីៗនេះ នៅក្នុងផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី NAPVAW IV (២០២៥–២០៣០) បានបញ្ជាក់ជាថ្មីម្តងទៀត អំពីចេតនារបស់រាជរដ្ឋាភិបាលក្នុងការធ្វើវិសោធនកម្ម និងផ្សព្វផ្សាយច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ ឱ្យស្របតាមបទដ្ឋានគតិយុត្តជាតិនិងអន្តរជាតិ ប៉ុន្តែការកំណត់ពេលវេលាដែលគួរឱ្យព្រួយបារម្ភនោះ គឺអូសបន្លាយរហូតដល់ឆ្នាំ២០៣០ ។

គម្លាតនានា ដែលមាននៅក្នុងច្បាប់ត្រូវបានរំលេចឡើងជាច្រើនលើកច្រើនសាមកហើយ។ តាំងពីឆ្នាំ ២០១៥ មក ក្រុមសង្គមស៊ីវិលបានលើកឡើងថាច្បាប់នេះមានចំណុចខ្វះខាតមួយចំនួនយ៉ាងច្បាស់ ហើយបានអំពាវនាវឱ្យធ្វើវិសោធនកម្ម។ នៅក្នុង សេចក្តីថ្លែងការណ៍មួយដែលចេញផ្សាយកាលពីឆ្នាំមុន ក្រុមអង្គការសង្គមស៊ីវិលបានលើកឡើងជាថ្មីថា ការពិនិត្យឡើងវិញទាំងស្រុងទៅលើច្បាប់នេះ គឺជាដំហានចាំបាច់មួយ ក្នុងការឆ្ពោះទៅដោះស្រាយវិបត្តិនេះ។ រាល់ឆ្នាំនៃការពន្យារពេល នាំឱ្យជីវិតមនុស្សជាច្រើននាក់ទទួលរងការបំផ្លិចបំផ្លាញ ឬត្រូវបាត់បង់។

យើងខ្ញុំ សូមអំពាវនាវសាជាថ្មីម្តងទៀតដល់រាជរដ្ឋាភិបាល ធ្វើវិសោធនកម្ម ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារជាបន្ទាន់ ឱ្យស្របទាំងស្រុងតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ព្រមទាំងធានាថាអ្នករងផលប៉ះពាល់ពីអំពើហិង្សាក្នុងគ្រួសារ និងសង្គមស៊ីវិល បានចូលរួមប្រកបដោយអត្ថន័យពេញលេញនៅគ្រប់ដំណាក់កាលទាំងអស់នៃ ដំណើរការនេះ ដើម្បីធានាថា ប្រជាជនគ្រប់រូបអាចរស់នៅចាកផុតពីអំពើហិង្សា។

ចំណុចខ្វះខាតសំខាន់ៗនៃច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះបច្ចុប្បន្ន និងស្នើឱ្យមានការកែលម្អនៅក្នុងការធ្វើវិសោធនកម្មនេះ រួមមាន៖

- ការខកខាន ដោយមិនបានដាក់បញ្ចូលមនុស្សគ្រប់រូបដែលរងហានិភ័យនៃអំពើហិង្សាក្នុងគ្រួសារ ឱ្យបានគ្រប់ជ្រុងជ្រោយ ទៅក្នុងវិសាលភាពច្បាប់។
- ការមិនបានកំណត់និយមន័យ កំណត់ជាបទល្មើសព្រហ្មទណ្ឌ និងរៀបរាប់អំពីទោសទណ្ឌ ចំពោះការរំលោភបំពានផ្លូវកាយ ផ្លូវភេទ ផ្លូវអារម្មណ៍/ផ្លូវចិត្ត និងផ្នែកសេដ្ឋកិច្ច ដែលអាចធ្វើឱ្យគេអាចបកស្រាយច្បាប់នេះ តាមទស្សនៈផ្ទាល់ខ្លួន និងបើកឱកាសឱ្យមាននិទណ្ឌភាព។
- ការគាំទ្រដោយប្រយោល នូវការប្រើអំពើហិង្សាក្នុងហេតុផល ថាជាវិធីក្នុងការ«ផ្តល់ដំបូន្មាន/ប្រៀនប្រដៅ/ដាស់តឿនក្រើនរំលឹក» ដល់ប្តីឬប្រពន្ធ កូន និងអ្នកនៅក្នុងបន្ទុក (មាត្រា៨) ដែលសិទ្ធិបែបនេះក៏ត្រូវបានផ្តល់ដល់ឪពុកម្តាយផងដែរ នៅក្នុងក្រមរដ្ឋប្បវេណី (មាត្រា១០៤៥) ។
- ការអត់ឱនចំពោះអំពើហិង្សា «ស្រាល» ។ ច្បាប់នេះចែងថា បទល្មើសឧក្រិដ្ឋ និងបទល្មើសមជ្ឈិម «ធ្ងន់ធ្ងរ» ត្រូវតែជាកម្មវត្ថុនៃបណ្តឹងអាជ្ញា (មាត្រា១៩) ក៏ប៉ុន្តែ ច្បាប់ជាតិទាំងនោះមិនបានឱ្យនិយមន័យនៃបទល្មើសមជ្ឈិម «ធ្ងន់ធ្ងរ» ឡើយ ដែលជាការអនុញ្ញាតឱ្យអាជ្ញាធរមិនចាត់វិធានការតាមនីតិវិធីព្រហ្មទណ្ឌចំពោះអំពើហិង្សាក្នុងគ្រួសារ ដែលពួកគេចាត់ទុកថា «ស្រាល»។
- ការលើកទឹកចិត្តឱ្យប្រើការអប់រំ ការផ្សះផ្សា និងការសម្រុះសម្រួល ក្នុងករណីអំពើហិង្សាផ្លូវអារម្មណ៍/ផ្លូវចិត្ត អំពើហិង្សាផ្នែកសេដ្ឋកិច្ច និងករណីអំពើហិង្សាក្នុងគ្រួសារដែលជាបទល្មើសព្រហ្មទណ្ឌ «ស្រាល» (មាត្រា ១៣, ១៧, ២៦–២៧)។ គួរហាមឃាត់ការប្រើប្រាស់ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ សម្រាប់ដោះស្រាយរាល់ទម្រង់អំពើហិង្សាក្នុងគ្រួសារគ្រប់ករណីទាំងអស់ដែលមានចរិត ជាបទល្មើសព្រហ្មទណ្ឌ។
- ការមិនបានកំណត់ឱ្យបានគ្រប់ជ្រុងជ្រោយ នូវកាតព្វកិច្ចជាក់លាក់របស់អាជ្ញាធរនានា ក្នុងការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាក្នុងគ្រួសារ។
- ការមិនបានកំណត់ឱ្យបានគ្រប់គ្រាន់ និងលម្អិត អំពីនីតិវិធី និងកិច្ចការពារ ដែលត្រូវផ្តល់ជូនតាមរយៈដីកាការពារ និងសេចក្តីសម្រេចរដ្ឋបាលនានា។
- ការមិនបានកំណត់លើកញ្ចប់ថវិកាជាក់លាក់ចេញពីថវិកាជាតិ សម្រាប់ការអនុវត្តច្បាប់ កិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ និងសេវាគាំទ្រនានា។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

- ម៉ៅ ម៉ាប់ នាយិកាប្រតិបត្តិ អង្គការក្លាហាន ទូរសព្ទ៖ +៨៥៥ ៧៨ ៩៧៤ ០៤០
- អយ ម៉ារីនី ប្រធានគម្រោង អង្គការនារីដើម្បីសន្តិភាព (WPM) ទូរសព្ទ៖ +៨៥៥ ៨៦ ៨៦០ ៤៣៣
- ជឹម ចាន់នាង អគ្គលេខាធិការ NGO-CEDAW ទូរសព្ទ៖ +៨៥៥ ១២ ៦៦៨ ៨៥៣
- សេង រាសី នាយិកាប្រតិបត្តិ អង្គការសីលការ ទូរសព្ទ៖ +៨៥៥ ១៧ ៩៣៣ ៣៣៦
- រឹមផាត បុប្ផាក្លង ប្រធានកម្មវិធីតស៊ូមតិ និងបណ្តាញ នៃអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា ទូរសព្ទ៖ +៨៥៥ ៦៩ ៦០០ ២៥៧

ក្រុមការងារនៃអង្គការសង្គមស៊ីវិលដើម្បីធ្វើវិសោធនកម្មច្បាប់អំពើហិង្សាក្នុងគ្រួសារ រួមមាន៖

1. អង្គការបន្ទាយស្រី (Banteay Srei)
2. អង្គការគណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (NGO-CEDAW)
3. អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា (CRC-Cambodia)
4. អង្គការយេនឌ័រនិងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC)
5. អង្គការក្លាហាន (Klahaan Organization)
6. អង្គការទេស្សន:ពិភពលោកអន្តរជាតិនៅកម្ពុជា (World Vision Cambodia)
7. អង្គការកម្ពុជាដើម្បីសុខភាព និងការអប់រំសហគមន៍ (CHEC)
8. អង្គការនារីដើម្បីសន្តិភាព (WPM)
9. អង្គការភ្លែនអន្តរជាតិកម្ពុជា (Plan International-Cambodia)
10. អង្គការសម្ព័ន្ធខ្មែរដំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO)
11. សមាគមគាំពារស្ត្រីងាយរងគ្រោះ (ASVW)
12. អង្គការជំនួយជនបទ (RAO)
13. អង្គការទ្រទ្រង់ស្ត្រីខ្មែរ (COWS)
14. អង្គការអប់រំសុខភាព និងបរិស្ថាន (EHE)
15. អង្គការសីលការ (SILAKA)
16. សហភាពការងារកម្ពុជា (CLC)